**អាទិត្យទី១៧នៃរដូវធម្មតា**
**ព្រះសហគមន៍សន្តីម៉ារីញញឹម ចំការទៀន**
**ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១**
**"ជីវិត"**

បងប្អូនជាទីស្រឡាញ់
ថ្ងៃនេះ យើងបានឃើញរបៀបដែលព្រះយេស៊ូយកចិត្តទុកដាក់ជាមួយមហាជន នៅពេលនោះ ព្រះយេស៊ូបង្រៀនគេ។ ព្រះយេស៊ូបានចាប់អារម្មណ៍ ទោះបីគេសប្បាយចិត្តស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ទោះបីព្រះយេស៊ូបានណែនាំឱ្យគេជាសះស្បើយ ប៉ុន្តែដូចមនុស្សយើងទាំងអស់គ្នាគេកំពុងឃ្លាន។ ព្រះយេស៊ូមានសំណួរមួយដ៏សំខាន់ "**តើយើងទៅរកទិញអាហារឯណាមកចែកឱ្យអ្នកទាំងនេះបរិភោគបាន?**"។ ព្រះយេស៊ូយកចិត្តទុកដាក់ ព្រះយេស៊ូចាប់អារម្មណ៍អំពីសេចក្ដីត្រូវការដ៏សាមញ្ញបំផុតរបស់មហាជន គឺឃ្លានអាហារ។ ព្រះយេស៊ូបានសម្រុះសម្រួល ដើម្បីឱ្យគេមានអាហារបរិភោគ នៅពេលនោះព្រះយេស៊ូបានសាកល្បងដល់ក្រុមគ្រីស្តទូត **តើគេអាចធ្វើដូចម្ដេចបានដើម្បីចិញ្ចឹមមហាជនដូច្នេះ**? ប៉ុន្តែ អ្វីដែលសំខាន់បំផុតគឺព្រះយេស៊ូបានណែនាំឱ្យក្រុមគ្រីស្តទូតយកចិត្តទុកដាក់ តាមព្រះយេស៊ូមានព្រះហឫទ័យទុកដាក់លើមហាជននេះ។ ព្រះយេស៊ូបានចាប់អារម្មណ៍អំពីគេ ព្រះយេស៊ូចង់ឱ្យក្រុមគ្រីស្តទូតចាប់អារម្មណ៍អំពីហ្វូងចៀមដែលគេត្រូវតែថែរក្សា អស់ពីកម្លាំងកាយកម្លាំងចិត្ត។

សូមចាប់អារម្មណ៍ នៅពេលព្រះយេស៊ូប្រមូលបានតែនំប៉័ងប្រាំដុំនិងត្រីពីរកន្ទុយ ព្រះយេស៊ូមានព្រះបន្ទូលថា "**សូមឱ្យគេអង្គុយចុះ**"។ ប៉ុន្តែ ព្រះយេស៊ូមិនបានរើសកន្លែងធម្មតាទេ ព្រះយេស៊ូបានជ្រើសរើសកន្លែងមួយដូចលោកយ៉ូហានបានថែមថា "**នៅទីនោះមានស្មៅច្រើន**"។ ព្រះយេស៊ូបានយកចិត្តទុកដាក់មែនទែន ព្រះអង្គមិនឱ្យគេអង្គុយនៅកន្លែងដែលមានថ្ម មិនឱ្យគេអង្គុយនៅកន្លែងដែលមានបន្លា គឺព្រះអង្គឱ្យគេអង្គុយនៅកន្លែងដែលមានស្មៅយ៉ាងច្រើន។ ឱ្យគេអង្គុយយ៉ាងស្រួល ដើម្បីទទួលម្ហូបអាហារដែលព្រះយេស៊ូនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធបានចែកឱ្យគេ

បរិភោគយ៉ាងបរិបូរណ៍។ ព្រះយេស៊ូបានយកចិត្តទុកដាក់ យកចិត្តទុកដាក់ដល់កំពូល យកចិត្តទុកដាក់ឱ្យគេមានម្ហូបអាហារគ្រប់គ្រាន់ យកចិត្តទុកដាក់ឱ្យគេអង្គុយនៅកន្លែងដែលស្រួល មានស្មៅយ៉ាងច្រើន ដើម្បីឱ្យគេមានភាពកក់ក្ដៅនិងអំណរសប្បាយរួមជាមួយគ្នា។

ថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលដដែលនេះសម្រាប់យើងដែរ **តើយើងធ្វើដូចម្ដេចដើម្បីយកចិត្តទុកដាក់ដល់បងប្អូនឯទៀតៗ?** មិនមែនយកចិត្តទុកដាក់ទូទៅ គឺយកចិត្តទុកដាក់យ៉ាងជាក់ស្ដែងដល់បងប្អូនដែលមានសេចក្ដីត្រូវការ ដល់បងប្អូនដែលកំពុងមានទុក្ខលំបាក។ នៅក្នុងអត្ថបទទី២ ថ្ងៃនេះលោកប៉ូលបានបង្ហាញអំពីមូលហេតុ យើងទាំងអស់គ្នាយើងជាគ្រួសារតែមួយ។ ប៉ុន្មានខែកន្លងមក ខ្ញុំតែងនិយាយថា ពិតមែនយើងជាគ្រួសារតែមួយ។ ប៉ុន្តែថ្ងៃនេះ យើងស្ដាប់មូលហេតុអ្វីយើងជាគ្រួសារតែមួយ ដោយសារយើងមានព្រះបិតាដែលស្រឡាញ់យើងពិតមែន។ ដោយសារយើងមានព្រះបិតាដែលបានបង្កើតយើងពិតមែន លោកប៉ូលបន្ថែមថា "**យើងមានព្រះកាយតែមួយ យើងមានព្រះវិញ្ញាណដ៏វិសុទ្ធតែមួយ យើងមានសេចក្ដីសង្ឃឹមតែមួយ យើងមានព្រះអម្ចាស់តែមួយ យើងមានជំនឿតែមួយ យើងមានពិធីជ្រមុជទឹកតែមួយ យើងមានព្រះជាម្ចាស់តែមួយព្រះអង្គជាព្រះបិតារបស់មនុស្សទាំងអស់ ព្រះអង្គខ្ពង់ខ្ពស់លើសអ្វីៗទាំងអស់ ហើយព្រះអង្គធ្វើការដោយសារមនុស្សទាំងអស់ និងសណ្ឋិតនៅក្នុងមនុស្សទាំងអស់**"។ នេះជាមូលហេតុ ព្រះកាយតែមួយ ព្រះវិញ្ញាណដ៏វិសុទ្ធតែមួយ សេចក្ដីសង្ឃឹមតែមួយ ព្រះអម្ចាស់តែមួយ ជំនឿតែមួយ ពិធីជ្រមុជទឹកតែមួយ នេះជាមូលហេតុយើងជាគ្រួសារតែមួយ ដោយសារយើងមានប្រភពនៃជីវិតតែមួយ។ នៅក្នុងអង្គព្រះគ្រីស្ដ យើងជាព្រះកាយនៅក្នុងព្រះសហគមន៍យើងជាគ្រួសារតែមួយ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធយើងជាបងប្អូនគ្នា។ យើងមានសេចក្ដីសង្ឃឹម យើងមានសេចក្ដីស្រឡាញ់ យើងមានជំនឿតែមួយ ដើម្បីជម្រុញយើងឱ្យធ្វើដំណើររួមជាមួយគ្នា។ នេះជាមូលហេតុ យើងជាគ្រួសារតែមួយ ដែលត្រូវតែយកចិត្តទុកដាក់តាមព្រះយេស៊ូមានព្រះបន្ទូលនៅថ្ងៃនេះ។

លោកប៉ូលថែមទៀតថា "**គ្រួសាររបស់យើងដែលមានប្រភពនៅក្នុងព្រះបិតា ត្រូវតែមានឥរិយាបថអ្វីខ្លះដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់?**"។ នេះសំខាន់ណាស់ យើងមិនមែនដូចមនុស្សឯទៀតៗ យើងត្រូវតែមានឥរិយាបថដែលលោកប៉ូលបានបង្ហាញឱ្យយើងថ្ងៃនេះ "**ចូរបន្ទាបខ្លួន ចូរមានចិត្តស្លូតបូត និងចេះអត់ធ្មត់ ព្រមទាំងទ្រាំទ្រគ្នាទៅវិញទៅមកដោយសេចក្ដីស្រឡាញ់ សូមយកចិត្តទុកដាក់ថែរក្សាឯកភាពដែលមកពីព្រះវិញ្ញាណ ដោយយកសេចក្ដីសុខសាន្តធ្វើជាចំណងប្រាស្រ័យដើម្បីឱ្យយើងទាក់ទងគ្នា**"។ បងប្អូនជាទីស្រឡាញ់ នៅក្នុងនេះយើងបានឃើញទាំងអស់

យើងមើលប្រភពនៃគ្រួសារយើង យើងមើលរបៀបដែលគ្រួសារយើងត្រូវតែរស់នៅនៅក្នុងទំនាក់ទំនងជាប្រចាំ។

**បន្ទាបខ្លួន** ឥតមានម្នាក់ដែលធំជាងគេ ឥតមានម្នាក់ដែលត្រូវតែអង្គុយចាំ យើងទាំងអស់គ្នាយើងជាអ្នកបម្រើ យើងទាំងអស់គ្នាយើងជាអ្នកជួយគ្នាទៅវិញទៅមក។ នៅក្នុងព្រះសហគមន៍ នៅក្នុងសង្គម ឥតមានមេធំៗដែលមិនធ្វើអ្វីសោះ។ ខ្ញុំសូមរំលែកថាពាក្យ "**អ្នកបម្រើ**" ជាមូលដ្ឋាននៃជីវិតរបស់យើង ប្រសិនបើយើងមិនបន្ទាបខ្លួនដោយធ្វើជាមនុស្សដែលពោរពេញដោយអំណាចយើងមិនធ្វើអ្វីសោះ ជីវិតរបស់យើងគ្មានតម្លៃទេ។

ជុំយទៅវិញបន្ទាបខ្លួន ចិត្តស្លូតបូតនិង**ចេះអត់ធ្មត់** ប្រសិនបើយើងមិនចេះអត់ធ្មត់យើងលែងរវីរវល់ជាមួយបងប្អូនឯទៀតៗ ដែលត្រូវការនេះ ដែលត្រូវការនោះ។

និងព្រមទាំង**ទ្រាំទ្រគ្នា**ទៅវិញទៅមកដោយសេចក្ដីស្រឡាញ់ នេះជាឥរិយាបថរបស់យើង។

បងប្អូនជាទីស្រឡាញ់ នៅក្នុងបរិយាកាសកូវីដ-១៩នេះ យើងបានឃើញយើងមានព្រំដែនច្រើនដើម្បីជួយ ដើម្បីបង្កើតទំនាក់ទំនងដូចយើងចង់មាន ដើម្បីយកចិត្តទុកដាក់ដូចយើងចង់មាន។

យើងមានព្រំដែននៅក្នុងការសិក្សា ដោយសារការសិក្សាសព្វថ្ងៃមិនអាចទៅរៀននៅសាលាដូចធម្មតាបាន ដូច្នេះរបៀបដែលយើងរៀនពីចម្ងាយគឺជាព្រំដែនមួយ។

យើងមានព្រំដែននៅក្នុងជីវិតខាងផ្លូវវិញ្ញាណ ដោយសារយើងឥតមានសិទ្ធិទទួលអគ្គសញ្ញាដែលផ្តល់ជីវិតពីប៉ុន្មានខែមកហើយ។ ពីប៉ុន្មានខែមកហើយ យើងមានបងប្រុសបងស្រី យើងមានគ្រីស្តបរិស័ទរបស់យើងជាច្រើន ដែលមិនបានទទួលព្រះកាយព្រះគ្រីស្ត និងអគ្គសញ្ញាលើកលែងទោស ដោយសារយើងឥតមានសិទ្ធិជួបជុំគ្នាជាផ្លូវការនៅក្នុងសាសនា នេះជាព្រំដែនមួយទៀត។

យើងមានព្រំដែននៅក្នុងទំនាក់ទំនង ដោយសារយើងមិនអាចជួបជុំគ្នាជប់លៀង សប្បាយជាមួយគ្នា ទៅសួរសុខទុក្ខគ្នាដូចពីមុន។ នេះជាព្រំដែនមួយទៀត ដែលបានកើតឡើងនៅក្នុងបរិយាកាសនឹងស្ថានភាពនៃជំងឺកូវីដ-១៩។

យើងមានព្រំដែនមួយទៀតនៅក្នុងការថែរក្សាសុខភាព ទោះបីយើងចង់ជួយបងប្អូនរបស់យើងក៏យើងជួយមិនបាន។ ជាក់ស្ដែង យើងបានឃើញសុខាដែលជាគ្រីស្តបរិស័ទរបស់យើង ដែលកំពុងឈឺធ្ងន់ធ្ងរយើងយកចេញពីខេត្តតាកែវដើម្បីបញ្ជូនទៅភ្នំពេញមិនបាន ដោយសារជំងឺកូវីដ-១៩។ ទោះបីយើងចង់ធ្វើ ទោះបីយើងបានយកចិត្តទុកដាក់អស់ពីសមត្ថភាព ទោះបីយើងខិតខំរកមន្ទីរពេទ្យដើម្បីទទួលគាត់បាន ចុងក្រោយបំផុតឥតមានសិទ្ធិឆ្លងខេត្ត។ នេះជាព្រំដែនមួយទៀត ដែលណែនាំឱ្យយើងមិនយល់ ដោយសុខចិត្តទុកឱ្យមនុស្សម្នាក់ស្លាប់ ដោយសារយើងបង្កើតព្រំដែនដែលគ្មានអត្ថន័យ។

ដូច្នេះ ខ្ញុំសង្ឃឹមយើងអាចភ្ញាក់ស្មារតីដើម្បីមើលព្រំដែនដែលយើងបង្កើត **តើព្រំដែននីមួយៗមានផលប្រយោជដើម្បីថែរក្សាកូវីដ-១៩កុំឱ្យរាលដាលពិតមែន ឬទៅជាព្រំដែនដែលណែនាំឱ្យមនុស្សយើងស្លាប់ដូចគ្មានតម្លៃ?** ណែនាំឱ្យមនុស្សយើងបាត់បង់សេចក្ដីសង្ឃឹម ដោយសារយើងបង្កើតព្រំដែនដែលធ្វើឱ្យមនុស្សយើងបានបង់សេចក្តីសង្ឃឹមអស់ហើយ។

បងប្អូនជាទីស្រឡាញ់ យើងត្រូវតែភ្ញាក់ស្មារតីគ្រប់ពេលវេលា កុំឱ្យយើងបង្កើតព្រំដែន កុំឱ្យយើងបង្កើតជញ្ជាំងដែលណែនាំឱ្យយើងស្លាប់បន្តិចម្តងៗ។ ណែនាំឱ្យយើងបាត់បង់ព្រលឹង បាត់បង់វិញ្ញាណ បាត់បង់ស្មារតី បាត់បង់កម្លាំងកាយកម្លាំងចិត្ត។ ប៉ុន្តែ សម្រាប់យើងជាគ្រីស្តបរិស័ទយ៉ាងតិចយើងនៅសល់ការអធិដ្ឋាន ដោយសារព្រះជាម្ចាស់ណែនាំឱ្យយើងដឹងថាព្រះអង្គមិនដែលចោលយើងសោះ។ ដូច្នេះ នៅក្នុងពេលវេលាពិបាកក៏ដោយ ទោះបីមនុស្សយើងតាមលោកិយយើងសម្រុះសម្រួលមិនបាន ទោះបីមនុស្សយើងតាមលោកិយយើងបង្កើតព្រំដែនដែលណែនាំឱ្យសេចក្ដីស្លាប់ហៀរចេញពីគ្រប់ទីកន្លែង យើងដឹងថាព្រះយេស៊ូយាងមកដើម្បីសង្គ្រោះយើង ព្រះយេស៊ូយាងមកដើម្បីឱ្យយើងមានជីវិត។ ដូច្នេះ ទោះបីយើងទីពឹងលើមនុស្សមិនបាន យើងអាចទីពឹងលើព្រះជាម្ចាស់។ ប្រសិនបើ ជីវិតត្រូវតែបញ្ចប់លើផែនដីនេះ យើងដឹងថាជីវិតរបស់យើងបន្តនៅស្ថានបរមសុខតទៅទៀត។

ដូច្នេះ យើងបន្តការពារថែរក្សាការអធិដ្ឋានរបស់យើង ការពារថែរក្សាសេចក្តីសង្ឃឹមរបស់យើង ជំនឿរបស់យើង សេចក្ដីស្រឡាញ់របស់យើង ដោយដឹងថាយ៉ាងតិចយើងមានព្រះជាម្ចាស់ដែលមិនចោលយើង។ យើងអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក ដោយទីពឹងលើព្រះជាម្ចាស់ ដោយសារមានតែព្រះជាម្ចាស់ដែលអាចសង្គ្រោះយើង មានតែព្រះជាម្ចាស់ដែលអាចប្រទានជីវិតអស់កល្បជានិច្ចឱ្យយើងខ្ញុំ។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ផ្មឹតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ